FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ការប្រើប្រាស់ជីអាសូត លើដំណាំស្រូវ

**នៅ**ប្រទេសកម្ពុជាយើង ដំណាំស្រូវត្រូវការស្រូបយកអាសូតសុទ្ធ ប្រហែល ១៦,៨ គ.ក្រ ដើម្បីផលិតគ្រាប់ស្រូវ ១000 គ.ក្រ។ ដូច្នេះដើម្បីផ្តល់ទិន្នផលចន្លោះពី ១,៥ ទៅ ២ ត/ហ.ត ដំណាំស្រូវនឹងត្រូវការស្រូបយកអាសូតប្រហែល ២៥ ទៅ ៣០ គ.ក្រ/ហ.ត។ ការផ្តល់អាសូតពីធម្មជាតិ ដូចជាពីដី ពីទឹកស្រោចស្រព ពីទឹកភ្លៀង និងពីសកម្មភាពរបស់ពពួកមីក្រូសារពាង្គកាយ គឺនៅចន្លោះប្រហែលពី ៣០ ទៅ ៦០ គ.ក្រ/ហ.ត។ មិនមែនគ្រប់អាសូតទាំងអស់ក្នុងដីសុទ្ធតែមានភាពសេរីអាចឲ្យដំណាំស្រូវយកបានទេ។ អាសូតខ្លះ ត្រូវបានបាត់បង់តាមការភាយឡើង ការជ្រាបចុះ ការហូរចេញ ការស្រូបយករបស់ស្មៅ ឬដោយពពួកមីក្រូសារពាង្គកាយក្នុងដី។

**ប្រភេទ**ដីខ្សាច់ ច្រើនមានបរិមាណសារធាតុសរីរាង្គតិច ហើយច្រើនស្ថិតនៅតំបន់ទំនាបអាស្រ័យរបបទឹកភ្លៀង រីឯប្រភេទដីល្បាប់ចាស់ ដែលសម្បូរដោយសារធាតុសរីរាង្គ ស្ថិតនៅក្នុងដីទំនាបលិចទឹក។ ការកើនឡើងនៃទិន្នផលតាមកម្រិតកំណត់នោះ មិនអាចទទួលបានឡើយប្រសិនបើមិនប្រើជីអាសូតតាមរយៈជីគីមី ឬជីសរីរាង្គទេនោះ។

**ដើម្បី**ប្រើប្រាស់ជីឲ្យមានប្រសិទ្ធភាព និងលក្ខណៈសេដ្ឋកិច្ចខ្ពស់ ក្នុងការបង្កើនទិន្នផលស្រូវ ត្រូវពិចារណានូវកត្តាសំខាន់ៗមួយចំនួនដូចខាងក្រោម៖






## អ្វីដែលជាកត្តាកំណត់ទិន្នផល?

**ជី**អាសូតមិនអាចជំនួសមុខឲ្យកង្វះខាតទឹក ឬកង្វះខាតសារធាតុចិញ្ចឹមផ្សេងៗទៀតដូចជាផូស្វ័រ និង ប៉ូតាស្យូម បាននោះទេ។

**ពេល**ខ្លះសារធាតុផូស្វ័រ ឬក៏សារធាតុចិញ្ចឹមផ្សេងៗទៀត អាចកំណត់ការលូតលាស់របស់រុក្ខជាតិខ្លាំងជាងសារធាតុអាសូតទៅទៀត។ការបន្ថែមជីអ៊ុយរ៉េដោយមិនបានដាក់ធាតុផូស្វ័រ ទៅលើប្រភេទដីជាច្រើនក្នុងប្រទេសកម្ពុជា មិនអាចបង្កើនទិន្នផលឡើយ គួរចងចាំថា ជីអាសូតគួរតែប្រើឲ្យមានតុល្យភាពជាមួយសារធាតុចិញ្ចឹមផ្សេងៗទៀត ឬកត្តាផ្សេងៗ។